# ក្របខណ្ឌភាពជាដៃគូរបស់ធនាគារពិភពលោកប្រចាំកម្ពុជា សម្រាប់ឆ្នាំ២០២៥-២០២៩
## កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំពិគ្រោះយោបល់ជាមួយកអង្គការសង្គមស៊ីវិល
## ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣
## សណ្ឋាគារ Raffles Le Royal, ភ្នំពេញ

នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៣ ការិយាល័យរបស់ធនាគារពិភពលោកប្រចាំនៅកម្ពុជា បានបើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ ជាមួយអង្គការសង្គមស៊ីវិល និងតំណាងសមាគមយុវជន, ស្ថាប័នអប់រំជាន់ខ្ពស់ និងអង្គការជង្រុកគំនិត ដើម្បីពិភាក្សាប្រមូលគំនិតសម្រាប់រៀបចំឯកសារក្របខណ្ឌភាពជាដៃគូប្រចាំប្រទេសកម្ពុជា សម្រាប់ឆ្នាំ ២០២៥-២០២៩ ដែលសរសេរកាត់ជាអង់គ្លេសថា CPF។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងផ្ទាល់ ជាមួយអ្នកចូលរួមចំនួន ៤៥នាក់ (សូមមើលឧបសម្ព័ន្ធភ្ជាប់មកជាមួយ)។

## ទិដ្ឋភាពរួម

កិច្ចពិគ្រោះយោបល់បានផ្តើមឡើងជាមួយនឹងប្រសាសន៍ស្វាគមន៍ របស់លោកស្រី Maryam Salim, ប្រធានគ្រប់គ្រងរបស់ធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា។ កិច្ចប្រជុំមានការធ្វើបទបង្ហាញជូនអ្នកចូលរួម ស្តីពីវឌ្ឍនភាព, បញ្ហាប្រឈម និងកាលានុវត្តភាពនៅកម្ពុជា ដូចមានលើកឡើងនៅក្នុងការវិភាគជាប្រព័ន្ធរបស់ធនាគារពិភពលោកអំពីស្ថានភាពក្នុងប្រទេស (World Bank's Systematic Country Diagnosis) អមជាមួយសេចក្តីសង្ខេបសំណើសម្រាប់រៀបចំ CPF។ បទបង្ហាញទាំងអស់ត្រូវបានរៀបចំធ្វើឡើង និងបង្ហាញជូនអង្គប្រជុំ ដោយបុគ្គលិករបស់ធនាគារពិភពលោក។ ឯកសារទាំងនេះអាចរកបាននៅក្នុងវេបសាយនេះ Cambodia CPF FY25-29 consultation website។

បន្ទាប់ពីពិធីបើក អ្នកចូលរួមត្រូវបានចែកជាក្រុមតូចៗ ផ្អែកតាមលទ្ធផលរំពឹងទុកកម្រិតខ្ពស់ (High Level Outcomes/HLO) ដើម្បីធ្វើការពិភាក្សាលើសំណួរចំនួនបួន។ ខាងក្រោមជាចម្លើយសង្ខេបដែលស្រង់ចេញពីវគ្គពិភាក្សាក្នុងកិច្ចប្រជុំនោះ៖

| **សំណួរទី១៖ តើអ្វីខ្លះជាបញ្ហាបីនៅលំដាប់លើគេ ដែលក្រុមធនាគារពិភពលោកគួរផ្តោតការយកចិត្តទុកដាក់លើ សម្រាប់រយៈពេល ៤ ទៅ ៥ឆ្នាំខាងមុខ?** |
|---|
| **HLO 1 –** អ្នកពិភាក្សាក្នុងក្រុមនេះ បានស្នើឱ្យធនាគារពិភពលោកផ្តោតលើជំនាញ សម្រាប់ការងារបៃតងប្រកបដោយចីរភាព ដើម្បីជួយដល់យុវជនកម្ពុជា រួមជាមួយនឹងការអប់រំបឋមសិក្សា និងការអប់រំកុមារតូច និងអាហារូបត្ថម្ភរួម ដោយសង្កត់ធ្ងន់លើក្រុមប្រជាជនដែលខ្វះខាត។<br><br>ពួកគេបានឱ្យយោបល់ថា ធនាគារពិភពលោកគួរពិចារណាជួយថែមទៀតក្នុងការកែលម្អការចំណាយសាធារណៈ រួមជាមួយការវិនិយោគកាន់តែច្រើនទៅលើធនធានមនុស្ស, សេវាសង្គម, ការអប់រំ និងការបណ្តុះបណ្តាល TVET។ លើសពីនោះ ពួកគេបានធ្វើការកត់សម្គាល់លើតម្រូវការសម្រាប់ការថែទាំសុខភាព ដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាព ផងដែរ។ |

**HLO 2 –** អ្នកចូលរួមពិភាក្សាអំពី HLO2 បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការអប់រំដែលមានគុណភាពរឹងមាំល្អ។ ពួកគាត់បានលើកឡើងពីភាពចាំបាច់ក្នុងការគាំទ្រដល់ការបណ្តុះបណ្តាល ដោយផ្តោតជាពិសេសលើការបង្កើនផលិតភាពកសិកម្ម (ដោយគេចាត់ទុកថា កសិកម្មនៅតែមានសារៈសំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា), ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច ដោយដោះស្រាយបញ្ហាប្រឈមក្នុងការចុះបញ្ជីអាជីវកម្ម, ការកែលម្អប្រព័ន្ធពន្ធដារ និងការប្រយុទ្ធប្រឆាំងនឹងការគេចពន្ធ។ ពួកគាត់ក៏បានធ្វើការកត់សម្គាល់បន្ថែមដែរពីតម្រូវការក្នុងការដោះស្រាយបញ្ហាបំណុល ដែលកំពុងកើនឡើង ជាពិសេសក្នុងចំណោមកសិករ។

អ្នកពិភាក្សាបានលើកឡើងពីតម្រូវការឱ្យពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់, បញ្ហាប្រឈមនៃអំពើពុករលួយ, កង្វះការប្រកួតប្រជែងដោយយុត្តិធម៌, និងការិយាធិបតេយ្យដ៏ស្មុគស្មាញ ដែលរារាំងដល់ការវិនិយោគឯកជន និងអាជីវកម្មក្នុងស្រុក។ ពួកគេបានសង្កត់ធ្ងន់លើភាពចាំបាច់ឱ្យមានគាំទ្រចំពោះហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសដើម្បីដោះស្រាយបញ្ហាស្ថានភាពផ្លូវ និងការសាងសង់ផ្លូវគ្មានគុណភាព ដោយសារអំពើពុករលួយ និងការត្រួតពិនិត្យគម្រោងខ្សោយ និងថ្លៃថាមពលខ្ពស់។ ដើម្បីកែលម្អការពិនិត្យតាមដាន និងគណនេយ្យភាពលើការងារសាធារណៈ ពួកគាត់បានលើកឡើងពីភាពចាំបាច់ធ្វើឱ្យប្រសើរឡើងនូវឯករាជ្យភាព និងអំណាចនៃស្ថាប័នសវនកម្ម ហើយពួកគាត់មានយោបល់ថា កម្មវិធីរបស់ធនាគារពិភពលោកអាចឆ្លើយតបចំពោះបញ្ហាទាំងនេះបានកាន់តែប្រសើរជាងមុន ដោយការបង្កើនគណនេយ្យភាពតាមរយៈគម្រោងដែលធនាគារពិភពលោកជាអ្នកផ្គត់ផ្គង់ហិរញ្ញវត្ថុ។

**HLO 3 –** អ្នកពិភាក្សាលើ HLO 3 បានទាក់ទាញការយកចិត្តទុកដាក់លើភាពចាំបាច់ឱ្យផ្តោតទៅលើជំនាញសម្រាប់ក្រុមជនងាយរងគ្រោះ ពិសេសជំនាញកសិកម្មឆ្លាតវៃអាកាសធាតុ (ឧទាហរណ៍ ការដាំស្រូវធន់នឹងអាកាសធាតុ), ភាពចាំបាច់បង្កើនលទ្ធភាពរកបានហិរញ្ញវត្ថុសម្រាប់ផលិតកម្មកសិកម្ម និងសម្រាប់ដោះស្រាយបញ្ហាបំណុលអាជីវកម្មខ្នាតតូច, ភាពចាំបាច់បង្កើនលទ្ធភាពទទួលបានដី ទឹក និងអគ្គិសនីប្រើប្រាស់សម្រាប់ទ្រទ្រង់ជីវភាពឱ្យប្រសើរ, និងភាពចាំបាច់បង្កើនហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងថាមពល សម្រាប់ទ្រទ្រង់ដល់ការធ្វើពាណិជ្ជកម្ម។

មានការផ្តល់យោបល់ឱ្យមានការវិនិយោគពហុវិស័យកាន់តែច្រើនឡើង; បង្កើនកិច្ចការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) សម្រាប់កសិកម្មឆ្លាតវៃអាកាសធាតុ; លើកកម្ពស់បច្ចេកវិទ្យាសមស្របសម្រាប់ការចាប់ផ្តើមអាជីវកម្មក្នុងស្រុក; និងការកំណត់អត្តសញ្ញាណផលិតផលសម្រាប់ទាំងការនាំចេញ និងបម្រើតម្រូវការរបស់ទីផ្សារក្នុងស្រុក។ អ្នកពិភាក្សាក៏បានលើកឡើងដែរអំពីតម្រូវការឱ្យបង្កើនឥទ្ធិពលនៃគោលនយោបាយអាកាសធាតុ ដោយកត់សម្គាល់ថា កម្ពុជាមានគោលនយោបាយល្អហើយ ប៉ុន្តែមានបញ្ហាជាមួយការអនុវត្ត។

ចំណុចមួយទៀតដែលអ្នកពិភាក្សាបានលើកឡើងថាមានសារៈសំខាន់ដែរនោះ គឺការលៃលកដោះស្រាយបញ្ហាត្រួតស៊ីគ្នានៃសកម្មភាពការងាររបស់ដៃគូអភិវឌ្ឍន៍ និងការធ្វើការពាក់ព័ន្ធជាមួយប្រជាជន និងសហគមន៍ក្នុងមូលដ្ឋាន។

**សំណួរទី២៖ ដោយមើលទៅលើឧត្តមភាពប្រៀបធៀបដែលធនាគារពិភពលោកកំពុងមាន តើនៅក្នុងផ្នែកអ្វីខ្លះនៅកម្ពុជាដែលធនាគារពិភពលោកគួរធ្វើសកម្មភាពតិចជាងមុន?**

**HLO1-** អ្នកចូលរួមជាច្រើនបានលើកទឹកចិត្តឱ្យធនាគារពិភពលោកវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ និងលទ្ធភាពទទួលបានទុនសម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយក៏មានការលើកឡើងផងដែរអំពីសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាធនធានមនុស្ស, ការផ្តល់សេវាសង្គម, ការថែទាំសុខភាព, ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអភិវឌ្ឍជំនាញសម្រាប់រកបានការងារល្អ។

**HLO 2-** អ្នកចូលរួមបានធ្វើការកត់សម្គាល់ថា ជ្បិតតែធនាគារពិភពលោកបានជួយក្នុងវិស័យអប់រំ ២០ឆ្នាំកន្លងមក ហើយក្តី លទ្ធផលនៃការសិក្សារបស់សិស្សអត់មានការរីកចម្រើនទេ។ ពួកគេបានស្នើថា ធនាគារពិភពលោកគួរតែពិនិត្យមើលឡើងវិញនូវដើមហេតុនៅពីក្រោយការសម្រេចបានវឌ្ឍនភាពតិចតួច នៅក្នុងវិស័យអប់រំនេះ។

**សំណួរទី៣៖ តើលោកអ្នកយល់ឃើញដូចម្តេចដែរអំពី លទ្ធផលរំពឹងទុកកម្រិតខ្ពស់ (HLO) និង គោលបំណង ដែលបានស្នើឡើងសម្រាប់រៀបចំក្របខណ្ឌ CPF នេះ?**

**HLO 1 –** ជារួម HLO ដែលបានស្នើឡើង ទទួលបានការគាំទ្រពីសំណាក់អ្នកចូលរួម។ ក្រុមពិភាក្សា HLO1 បានស្នើថា គួរតែមានការផ្តោតឱ្យបានច្រើនថែមទៀត ទៅលើបរិយាបន្នសង្គម អមដោយសូចនាករសមស្រប។

**HLO 2 –** អ្នកចូលរួមបានលើកឡើងថា សំណើ HLOs ទាំងអស់ មានការពាក់ព័ន្ធ និងមានប្រសិទ្ធភាព ប៉ុន្តែពួកគេបានអំពាវនាវឱ្យផ្តោតថែមទៀតទៅលើអភិបាលកិច្ច, តម្លាភាព និងវិនិយោគបន្ថែមទៅលើក្រុមប្រជាជនងាយរងគ្រោះ។

**HLO 3 –** អ្នកចូលរួមបានស្នើឱ្យដាក់បញ្ចូលគោលដៅនៃការបន្សាំអាកាសធាតុ, ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ និងភាពធន់អាកាសធាតុ ទៅក្នុងឯកសារក្របខណ្ឌផង។ ពួកគេបានថែមយោបល់ទៀតថា រដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍, អង្គការក្រៅរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល និងផ្នែកឯកជន គួរសហការគ្នាឱ្យបានជិតស្និទ្ធ (ឬអាចពិចារណាបង្កើតសូចនាករតាមដានរួមគ្នា ក៏បានដែរ)។

**សំណួរទី៤៖ តើតាមរបៀបណាខ្លះដែលធនាគារពិភពលោកអាចឆ្លើយតបបានកាន់តែប្រសើរ ទៅនឹងបញ្ហាប្រឈមអន្តរវិស័យពាក់ព័ន្ធជាមួយ៖**

- **ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ**
- **អភិបាលកិច្ច និងសមត្ថភាពរបស់ស្ថាប័ន**
- **សមភាពយេនឌ័រ និងបរិយាបន្ន**

**HLO 1 –** ក្រុមនេះបានស្នើថា អង្គការសង្គមស៊ីវិល, អង្គការក្រៅរដ្ឋាភិបាល និងរដ្ឋាភិបាល គួរធ្វើការតាមដានពិនិត្យរួមគ្នាលើកម្មវិធីរបស់ធនាគារពិភពលោក ហើយស្ថាប័នឯកជននឹងជួយធនាគារពិភពលោក ក្នុងការដោះស្រាយបញ្ហាប្រឈមដែលមានលក្ខណៈអន្តរវិស័យ ឱ្យបានប្រសើរជាងមុន។ មានការលើកឡើងថែមទៀតថា អង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល នៅបន្តដើរតួនាទីស្នូលក្នុងការតាមដានមើលឥទ្ធិពលរបស់កម្មវិធីជំនួយ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាសមភាពយេនឌ័រ និងបរិយាបន្ន ពួកគាត់បានសង្កត់ធ្ងន់លើការជំរុញភាពជាអ្នកដឹកនាំរបស់ស្ត្រី តាមរយៈគំរូ និងការយល់ដឹង រួមទាំងនៅកម្រិតសហគមន៍ផងដែរ។ ពួកគាត់ក៏បានលើកទឹកចិត្តដែរឱ្យធ្វើការពាក់ព័ន្ធជាមួយយុវជន ជាពិសេសដើម្បីគាំទ្រដល់ការងារបៃតង។

**HLO 2 –** ការផ្តល់ហិរញ្ញប្បទាន និងការគាំទ្រសម្រាប់សមត្ថភាពស្ថាប័នថែមទៀត ត្រូវបានលើកឡើងថាមានប្រសិទ្ធភាពបំផុតសម្រាប់ការដោះស្រាយបញ្ហាប្រឈមអន្តរវិស័យ។ ក្រុមនេះបានធ្វើការកត់សម្គាល់ពីសារៈសំខាន់សម្រាប់ការឆ្លើយតបមិនត្រឹមតែទៅនឹងបញ្ហាយេនឌ័រប៉ុណ្ណោះទេ ប៉ុន្តែដល់បញ្ហា LGBTQ ផងដែរ។ អ្នកពិភាក្សាបានស្នើថា អភិបាលកិច្ច និងការពង្រឹងស្ថាប័ន គួរតែត្រូវបានដាក់ជា HLO មួយដោយឡែកតែម្នាក់ឯង មិនគួរដាក់ជាបញ្ហាអន្តរវិ

| |
|---|
| ស័យទេ ដើម្បីទាញការយកចិត្តទុកដាក់ និងធនធានឱ្យបានគ្រប់គ្រាន់ សម្រាប់ឱ្យវាបញ្ចេញឥទ្ធិពលជាដុំកំភួននៅក្នុងកិច្ចការអភិវឌ្ឍន៍។<br><br>**HLO 3 –** ក្រុមដែលឆ្លើយតបលើ HLO3 បានស្នើឱ្យគិតគូរបញ្ចូលក្រុមងាយរងគ្រោះកាន់តែច្រើន និងប្រកបដោយអត្ថន័យ រួមមាន ស្ត្រី ជនក្រីក្រ និងជនមានពិការភាព ដើម្បីឆ្លើយតបបានកាន់តែប្រសើរទៅនឹងបញ្ហាប្រឈមអន្តរវិស័យទាំងនេះ។ ក្រុមនេះក៏បានស្នើដែរថា អភិបាលកិច្ចល្អគួរតែដាក់ធ្វើជា HLO មួយ ឬជាសូចនាករមួយ ដើម្បីពង្រឹងការចូលរួមសកម្មរបស់ពលរដ្ឋនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ |

## ឧបសម្ព័ន្ធ

| **អ្នកចូលរួម** | **តំណាងអង្គការមានវត្តមានចូលរួម** |
|---|---|
| ៤៥នាក់ | វេទិកាអង្គការមិនមែនរដ្ឋាភិបាល<br>រចនាស្ត្រី<br>ការអភិវឌ្ឍទីជនបទភាគឦសាន (NRD)<br>ព្រះពុទ្ធសាសនាដើម្បីសកម្មភាពអភិវឌ្ឍន៍សង្គម (BSDA)<br>Action Aid Cambodia (AAC)<br>អង្គការតម្លាភាពកម្ពុជា (TIC)<br>Save the Children International (SCI)<br>គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)<br>Credit Union Foundation Australia (CUFA)<br>Community Translation  Organization (CTO)<br>សុខភាពគ្រួសារកម្ពុជា (FHC)<br>អង្គការវឌ្ឍនភាពសហគមន៍ (CAO)<br>សាមគ្គី<br>អង្គការជនពិការអន្តរជាតិ (HI)<br>Aide et Action (AeA)<br>Heifer International<br>សកម្មភាពប្រជាជនសម្រាប់ការអភិវឌ្ឍដោយបរិយាបន្ន (PAfID)<br>សម្ព័ន្ធសម្រាប់សុចរិតភាព និងគណនេយ្យភាពសង្គម (CISA)<br>វិទ្យាស្ថានបម្រើអ្នកសម្របសម្រួលការងារអភិវឌ្ឍន៍ (VBNK)<br>ការីតាស អូស្ត្រាលី<br>NUPPUN<br>មជ្ឈមណ្ឌលសម្រាប់ការសិក្សាគោលនយោបាយ (CPS)<br>សមាគមយុវជនខ្មែរ (KYA)<br>ជំនួយផ្នែកច្បាប់កម្ពុជា (LAC)<br>វេទិកាអនាគត<br>មជ្ឈមណ្ឌលវិភាគបញ្ហាអភិវឌ្ឍន៍ (ADIC)<br>ការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) |

| | |
|---|---|
| | អង្គការទស្សនៈពិភពលោកកម្ពុជា (WVI)<br>ជំនួយផ្នែកច្បាប់កម្ពុជា (LAC)<br>អង្គការទិន្នន័យអំពីការអភិវឌ្ឍន៍ (ODC)<br>វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)<br>សាកលវិទ្យាល័យជាតិគ្រប់គ្រង (NUM)<br>សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA)<br>សាកលវិទ្យាល័យកម្ពុជា (HC)<br>អង្គការសម្ព័ន្ធភាពសម្រាប់ការផ្លាស់ប្តូរវិវាទ (ACT)<br>អង្គការស្តារកម្ពុជា<br>វិទ្យាស្ថានអន្តរជាតិសម្រាប់ការកសាងឡើងវិញជនបទ (IIRR)<br>Planète Enfants & Développement |